# ផ្ទេរឯកសារសមាគម យឺតពេលប្រសើរជាងអត់ធ្វើ





**ប្រូវិដិន** : កាលពីថ្ងៃអាទិត្យ ទី២៧ ខែកុម្ភៈ ឆ្នាំ២០១១ សមាគមខ្មែរនៃរដ្ឋរ៉ូដអៃឡិន្ត បានរៀបចំកិច្ចទទួលឯកសារជាផ្លូវការមួយនៅអាគាររបស់សមាគមលេខ១៦៨ ផ្លូវហានូវើ ។ ចំពោះភាគីសមាគមជាអ្នកទទួលឯកសារដែលដឹកនាំដោយលោកអនុប្រធាន ឡាក់ ស៊ីម និង សមាជិក៣រូបទៀតគឺ ១-លោក ប្រាក់ ឡាវង្ស ទីប្រឹក្សា ២-អ្នកស្រី ចិន្តា អគ្គលេខាធិការ ៣-អ្នកស្រី ស៊ីម អែនជូលិកា អគ្គហិរញ្ញិក ។ ចំណែកឯភាគីប្រគល់ឯកសារគឺលោក រ័ត្ន សារិន អតីតប្រធានសមាគមអាណត្តិឆ្នាំ២០០៩ និងអតីតសមាជិកក្នុងអាណត្តិឆ្នាំ២០០៩ ៣រូបដែរ គឺ ១-លោក សែម ឈឹម អតីតអនុប្រធាន ២-លោក រស់ រតនៈ អតីតអគ្គលេខាធិការរង ៣-លោក សាយ សារាត់ អតីតទីប្រឹក្សា និងមានបុគ្គលពីររូបទៀតចូលរួមជាសក្ខីភាពគឺ ១-លោក តារារិទ្ធ ជាអតីតគណៈកម្មការរៀបចំការបោះឆ្នោត ២-លោក ហេង សុវណ្ណ អ្នកយកព័ត៌មានការសែតខ្មែរប៉ុស្តិ៍ ។

នៅក្នុងឱកាសនោះដែរ លោកអនុប្រធាន ឡាក់ ស៊ីម ធ្វើការថ្លែងអំណរគុណចំពោះលោក សារិន រ័ត្ន និង សមាជិកដែលលោកបានខិតខំខ្នះខ្នែងរៀបចំឯកសារសំខាន់ៗមានដូចជា: ឯកសារប្រាក់ចំណូល និងចំណាយផ្សេងៗ និងសំភារះមួយចំនួនទៀតដែល សមាគមបច្ចុប្បន្នត្រូវការជាចាំបាច់ ។ ចំណែកឯលោក រ័ត្ន សារិន វិញលោកក៏សូមអភ័យទោសចំពោះការយឺតយ៉ាវក្នុងការប្រគល់នូវឯកសារទាំងនេះដោយសារតែឯកសារមួយចំនួនខ្វះខាត ហើយលោកត្រូវស្វែងរកមកបំពេញបន្ថែមជូនសមាគម ។ លោកក៏បានបង្ហាញនូវឯកសារដែលបញ្ជាក់ ពីធានាគារស៊ីធីសែន (CITIZENS BANK) ថាលោកបានយកប្រាក់ទៅកក់ទីកន្លែងសំរាប់រៀបចំពិធីបុណ្យចូលឆ្នាំខ្មែរ ចំនួន៥៥០ដុល្លារមែន ហើយលោកក៏មិនយល់ដែរថា ហេតុអ្វីបានជាខាងឃ្លឹប បដិសេធថាមិនបានទទួលប្រាក់កក់ទៅវិញ? ពាក់ព័ន្ធ និងបញ្ហានេះ លោកឡាក់ ស៊ីម នឹងយកឯកសារដែលលោកទទួលបាននេះទៅបង្ហាញជូនម្ចាស់ឃ្លឹបម្តងទៀត ។ លោក រ័ត្ន សារិន ក៏បានបន្ថែមផងដែរថា : បើទោះបីជាលោកផុតអាណត្តិជាប្រធានសមាគមហើយក្តី លោកនៅតែរីករាយសហការជាមួយសមាគមគ្រប់ពេលដែលសមាគមត្រូវការរូបលោក ។

**គម្រោងរៀបចំបុណ្យចូលឆ្នាំខ្មែរនៅរ៉ូដអៃឡិន្ត :** ប្រធានសមាគមខ្មែរសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ចូលរួមធ្វើបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងកំសាន្តសប្បាយឱ្យបានគ្រប់គ្រប់គ្នាៗ ដើម្បីញ៉ាំងឱ្យពិធីនេះមានភាពអធិកអធម ដែលនឹងប្រព្រឹត្តធ្វើឡើងនៅថ្ងៃសៅរ៍ទី២៣ មេសា ២០១១ នៅឯ RHODES-ON THE-PAWTUXET, 60 Rhodes place, Cranston, RI 02905 កម្មវិធីនេះចាប់ផ្តើមពីម៉ោង៨ព្រឹក រហូតដល់ម៉ោង១២យប់ ដែលមានកម្មវិធីដូចជា :

***ម៉ោង ៨:០០ ព្រឹក ដល់ ម៉ោង ១២:០០ ថ្ងៃត្រង់***

- និមន្តព្រះសង្ឃ ប្រារព្ធពិធីតាមប្រពៃណីព្រះពុទ្ធសាសនាមានដូចជា: -ពិធីបង្សុកូល-ពិធីរាប់បាត្រ-ពិធីស្រង់ព្រះ និងពិធីពូនភ្នំខ្សាច់ជាដើម ។ល ។

***ម៉ោង ១២:០០ ថ្ងៃត្រង់ ដល់ ម៉ោង ៥:០០ ល្ងាច***

-ការលេងល្បែងប្រជាប្រិយខ្មែរ និងការបង្ហាញម៉ូតសំលៀកបំពាក់បុរាណខ្មែរ

-ការសំដែងក្បាច់រាំសម័យទំនើបដោយក្រុមកុមារា កុមារីខ្មែរ ចំនួន៣ក្រុមផងដែរ

***ម៉ោង ៥:០០ ល្ងាច ដល់ ម៉ោង ១២:០០ យប់***

-ការសំដែងរបាំបុរាណខ្មែរ-ការចាប់ឆ្នោតផ្សងសំណាង

-រាំលេងកំសាន្ត ជាមួយក្រុមតន្ត្រី H2O

សូមបញ្ជាក់ថាការរាំកំសាន្តនៅពេលយប់នឹងមានការលក់សំបុត្រមុននៅតាមហាងលក់ទំនិញ និងភោជនីយដ្ឋានខ្មែរនានា នៅក្នុងរ៉ូដអៃឡិន្ត ដែលមានតំលៃសំបុត្រ២០ដុល្លាក្នុង១នាក់ និង១០ដុល្លា សំរាប់ក្មេងដែលមានអាយុចាប់ពី៦ដល់១២ឆ្នាំ ៕






# Best Choice

## SKIN CARE & SPA

930 Washington Ave. Philadelphia .PA 19147
Tel: 267.519.9908. Fax: 267.519.9913
*Tracey Ling, Manager* **1.866.755.2088**



កម្មវិធីពិសេសជាវសេវាថែរក្សាស្បែកមុខ៥ដង និងថែមជូនពីរដងដោយឥតគិតថ្លៃ និងបញ្ចុះតំលៃ១៥ភាគរយទៅលើផលិតផលថែរក្សាស្បែកគ្រប់ប្រភេទ

ការផាត់មុខជាប្រចាំបញ្ចុះតំលៃ២០ភាគរយ

រាល់ការជាវផលិតផលស្បែកមុខ៥ដង នឹងទទួលបានការបន្ថែមមួយដងដោយ ឥតគិតថ្លៃនិងការបញ្ចុះតំលៃ១៥ភាគរយ ទៅលើការជាវផលិតផលថែរក្សា ស្បែកគ្រប់ប្រភេទ ។

Eyelash Conditioner ជាផលិតផលសំរាប់ចិញ្ចឹម និងផ្តល់សំណើមដល់រោមភ្នែកជួយឱ្យរោមភ្នែកលូតវែងក្រាស់ និងដុះច្រើនជាងមុន

Ohagi Product សំរាប់ព្យាបាលស្បែករុចខ្មៅទៅតាមវ័យស្បែក អាចម៉ុរុយ និងស្លាកជ្រាំជ្រួញ។ បណ្តុះស្បែកមុខជាថ្មីធ្វើឱ្យមុខម៉ត់រលោង ។

Plum Delite Plum Fruit
ជាផ្លែ ព្រូនសំរកទម្ងន់

Optrimax Body Gel
សំរាប់លាបលើពោះ និងរាងកាយទាំងមូល ធ្វើឱ្យពោះរៀបស្មើ ។

Beauty Body Gel ជួយបន្ទឹងស្បែកឱ្យហាប់ណែននៅត្រង់ដើមដៃ ត្រគាក ភ្លៅ និងក្បាលពោះ ។

Portable Steam Sauna ប្រើប្រាស់សំរាប់គ្រួសារ ជួយធ្វើឱ្យចរន្តឈាមដើរបានល្អ ស្បែក បញ្ចេញចោលនូវជាតិពុល និងកំចាត់ចោលជាតិខ្លាញ់ដែលលើស ។

Beauty Princess Cream
មកពីប្រទេសបារាំង សំរាប់ធ្វើឱ្យស្បែកស និងព្យាបាលអាចម៍រុយ

All Sun Block SPF 50-88-100-108
សំរាប់លាបការពារស្បែកពីពន្លឺព្រះអាទិត្យ និងមានធាតុអាកាស ក្តៅខ្លាំង

Brightening Cream
ប្រេងលាបឱ្យស្បែកសភ្លឺ

Strech Marks
ប្រេងជួយបមបាត់ស្នាមសង្វាបន្ទាប់ពីកើតមុន

Sakura
ថ្នាំជប៉ុនសម្រាប់បញ្ចុះទម្ងន់

EMU
បំបាត់ស្បែកជ្រីវជ្រួញ

Pearl Cream
លាបឱ្យស្បែកមុខឱ្យស ហើយទាញឱ្យតឹង មកពីជប៉ុន

Lose Weight Coffee
កាហ្វេធ្វើឱ្យទម្ងន់

Foot Patch
ថ្នាំបិទជើង សម្រាប់បូមជាតិពុលចេញពីខ្លួន

Stormach Massager
ម៉ាស៊ីនម៉ាស្សាពង្រាបក្បាលពោះ ធ្វើឱ្យពោះរាបស្មើ

Busto Lift ជាឈុតគ្រែមសំរាប់លាបលើសុដន់ និងថ្នាំគ្រាប់លេបសំរាប់ពង្រីក និងធ្វើឱ្យសុដន់តឹងណែនល្អមិនធ្លាក់

### ឯកទេសថែរក្សាស្បែក និងសុខភាព

- ជំនាញថែរក្សាផ្ទៃមុខនិងម៉ាហ្សាតាមបែបអឺរ៉ុប
- បច្ចេកវិទ្យាបញ្ចូលក្នុងស្បែកនូវអតិសុខុមនៃគ្រាប់ពេជ្រ
- សំរកទម្ងន់ និងកាត់បន្ថយខ្លាញ់ដែលលើស
- តុបតែងផាត់មុខជាអចិន្ត្រៃ
- ព្យាបាលស្បែកដែលមានពណ៌សម្បុរមិនល្អ
- ព្យាលបាលមុខកើតមុន
- ព្យាបាលស្បែកដែលប្រតិកម្មដោយសារធាតុគីមី
- ធ្វើសក់ជាប្រចាំ



# ភោជនីយដ្ឋាន ណាម វាង (ភ្នំពេញ)

## *Nam Vang Restaurant*

**571 Unit#1 Adams Svenue. Philadelphia, PA 19120**
**(inside Hong Kong Market) (215) 742-9488**





រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់សជាតិផ្លែឈើ ដូចជា: ទុរេន ឬ អាវូកាដូ ហើយជាពិសេសមានទឹកអំពៅស្រស់ៗ

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា :**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ថាំង ឆាសាច់គោ
- មីកន្ថាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា :**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬ មី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

**Open 7 days a week from 9a.m-9p.m**
**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**





# ក្រុមហ៊ុន ទេសចរណ៍

## CENTURY TRAVEL & SERVICE CENTER

**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Fax : 215-625-9395**
**Cell : 267-934-9888; Email : centuryphl@yahoo.com**

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

**OFFICE Hours :**
**Mon - Sat 10:00 A.M - 6:00 P.M**
**Sun : 12:00 P.M - 5:00 P.M**

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម

តមកទំព័រទី ០១

# អគ្គីភ័យនៅឡូត្តាន់...

ចុងក្រោយជាមួយនឹងភ្លើងឆេះផ្ទះលោកអស់ទៅហើយ។ លោកបានបន្តថា កូនក្មួយដែលរបួសដោយសារលោតចេញតាមបង្អួច ឬតាមទ្វារ បានត្រូវសប្បុរសជនជិតខាងនាំទៅពេទ្យជាបន្ទាន់ ដោយឡានទឹក ក្រុមអ្នកពន្លត់ភ្លើង និងឡានពេទ្យមានការយឺតយ៉ាវមកមិនទាន់។ លោកបានស្វែងរកកូនប្រុសជាទីស្រឡាញ់អាយុ១០ឆ្នាំ ឈ្មោះ ភីទ័រសន តាំង និងអាយុ៨ឆ្នាំ ឈ្មោះ ខេវិន តាំង តែរកមិនឃើញ ពីមន្ទីរពេទ្យវេលាម៉ោង៥ល្ងាច ទើបគេឱ្យដឹងថា កូនទាំងពីរស្លាប់ដោយផ្សែងក្នុងបន្ទប់ រួចត្រូវភ្លើងឆេះដុតរោលខ្លួន។





គ្រួសារលោក តាំង ផេង និងអ្នកស្រី ហួរ សោ និងកូនបីនាក់ ធ្វើបុណ្យកំណើតជូនលោក ផេង

គ្មាននរណាដឹងពីដើមហេតុច្បាស់លាស់នៃអគ្គីភ័យនោះទេ ការស៊ើបអង្កេតជាដំបូងបាននិយាយផ្សាយក្នុងកាសែតមេត្រូ នាថ្ងៃបន្ទាប់ថា ប្រដាប់រំលឹកឱ្យដឹងថាមានផ្សែងពេលឆេះផ្ទះនោះ ប្រហែលជាពុំមានទេ ហើយទំនងជាមានការតខ្សែភ្លើងខ្វាត់ខ្វែងមិនត្រឹមត្រូវច្រើនទៀតផង។ លោក តាំង ផេង បានបញ្ជាក់ថា ពេលកើតហេតុពុំមានមនុស្សនៅជាន់ក្រោមទេ ហើយក៏ពុំមាននរណាធ្វើម្ហូបអ្វីដែរ ដោយម្នាក់ៗនៅក្នុងបន្ទប់រៀងៗខ្លួន ខ្លះលង់ក្នុងដំណេកដោយធ្វើការវេនយប់ ហើយខ្លះទៀតកំពុងមើលកុនឬទូរទស្សន៍ ពុំបានដឹងថា ភ្លើងចាប់ផ្តើមឆេះនៅបន្ទប់ទទួលភ្ញៀវ នាជាន់ទី១ តែពុំមានការតខ្សែភ្លើងអ្វីប្លែសផ្លាសនោះទេ តាំងពីមកនៅផ្ទះនេះ ១៦ឆ្នាំមកហើយ រីឯប្រដាប់រំលឹកពីផ្សែង (Smoke detectors) មាន៦ដាក់ថ្មីនាពេលឆែកកាលពីជាងពីរឆ្នាំមុន ហើយថែមទាំងមានប្រដាប់លត់នៅផ្ទះបាយទៀតផង។

ស្រឡាំងកាំងនឹងផ្សែងភ្លើងពេញផ្ទះ កំពុងឆេះដល់បន្ទប់ប្អូនប្រុស ផេង ត្រាន ហៅ ឈិន អាយុ២៩ឆ្នាំ ប្រមូលកូនប្រុស ចសស៊ីន ត្រាន អាយុ១០ឆ្នាំ និងកូនស្រី ចាស្មីន ត្រាន អាយុ៨ឆ្នាំ រត់ចេញមកក្រៅតាមទ្វារ ធ្វើឱ្យឆេះរលាកមុខមាត់ ដៃជើងទាំងអស់គ្នា រីឯនាង សីណាត លិម អាយុ៣០ឆ្នាំ ខ្ចប់កូនអាយុ២ខែ អូសយក ម៉ាយកិល តាំង រត់ចេញបានមុនបន្តិច រីឯប្អូនប្រុសម្នាក់ទៀត ឈ្មោះ ហេងវ៉ាន់ ត្រាន អាយុ២៦ឆ្នាំ មិនអាចគេចខ្លួនតាមទ្វារ ក៏លោតតាមបង្អួចក្រោយផ្ទះ បណ្តាលឱ្យបាក់ជើង និងស្មា នាំយកទៅមន្ទីរពេទ្យបានភ្លាម។ ចំណែកឯកកូនប្រុសសម្លាញ់ចិត្តរបស់លោក ផេង និងអ្នកស្រី ហួរ ពុំមានឃើញរត់ចេញមកទេ ភីទ័រសន តាំង អាយុ១០ឆ្នាំ និង ខេវិន តាំង អាយុ៨ឆ្នាំ ក្រុមអ្នកពន្លត់ភ្លើងនិយាយបន្ទាប់ពីពេលកើតហេតុថា "កូនក្មេងពីនាក់បានត្រូវសន្លប់ដោយសារតែផ្សែង ហើយភ្លើងក៏បានដុតរោលខ្លួនបណ្តាលឱ្យស្លាប់ភ្លាមជាបន្ទាប់មកទាំងពីរនាក់"។





សំណាងអាក្រក់មិនមកតែឯកឯងទេ ថ្ងៃគ្រោះថ្នាក់នោះ ឡានទឹក ពន្លត់ភ្លើង មិនបានមករហ័សដូចសព្វដងទេ ក្រុមពន្លត់ភ្លើង៦១ជិតបំផុតបានត្រូវបិទដោយសារបញ្ហាថវិកា លោក ផេង ម្ចាស់ផ្ទះនិយាយថា ឡានទឹកមកដល់ពីរម៉ោងក្រោយ ប៉ុន្តែសេចក្តីរាយការណ៍និយាយថា ក្រុមពន្លត់ភ្លើងបានមកដល់កន្លែងកើតហេតុនៅ៥នាទី២០វិនាទី បន្ទាប់ពីការហៅ 9.1.1 ហើយបានប្រយុទ្ធនឹងភ្លើង៤២នាទី មុននឹងបង្ក្រាបភ្លើងបាន។ លោកអធិការក្រុងឡូវែលបាននិយាយប្រាប់កាសែតមេត្រូថា "ទោះជាមានការកាត់បន្ថយថវិកាក្រុមសង្គ្រោះពីអគ្គីភ័យក្តី ក៏ពេលនេះពុំអាចបន្ទោសពីល្បឿននៃក្រុមសង្គ្រោះបានទេ ដោយសារជាទូទៅ ឡានទឹកឆ្លើយតបបានក្នុងល្បឿនតិចជាង៥នាទី ហើយពេលច្រើនដងដល់ទៅជិត៨នាទីឯណោះ"។ មកទល់ពេលនេះមានការតវ៉ាប្រឆាំងនឹងការកាត់ថវិកានៃក្រុមសង្គ្រោះនោះយ៉ាងច្រើន ការបិទស្ថានីយ៦១ ដែលនៅជិតបំផុតនេះ អាចពន្យាពេលសង្គ្រោះដល់ទៅបីនាទីឯណោះ។ អ្នកឯកទេសនិយាយថា ១នាទីនៃភ្លើងអគ្គីភ័យមានសារសំខាន់ណាស់ ការយឺតយ៉ាវពី២នាទីទៅ៣នាទី ភ្លើងអាចរីកធំគុណនឹង៦ដង បានន័យថាទំហំធំពេញផ្ទះទាំងមូលទៅហើយ។





សមាគមខ្មែរ តំណាងដោយនាយិកា រ៉ង ស៊ន មានគុណសម្បត្តិច្រើនក្នុងការជួយយកចិត្តទុកដាក់ចំពោះក្រុមគ្រួសារដែលរងគ្រោះ។ មនុស្សជិតឆ្ងាយនៃសហគមន៍ ព្រមទាំងអ្នកភូមិរួមសង្កាត់ បានមកសំដែងការចូលរួមមរណទុក្ខជាច្រើនរយនាក់។ ក្នុងខណៈនេះក្រុមគ្រួសារនៅសំណាក់នាសណ្ឋាគារមួយដោយការគ្រប់គ្រងនៃកាកបាទក្រហម នាផ្លូវ "ប្រ៉ដ" ខាងជើង ហើយមកធ្វើបុណ្យបង្សុកូល នៅវត្តស៊ុរិយារង្សី ។ ក្រុមគ្រួសាររងគ្រោះ នាឱកាសនោះត្រូវការកិច្ចគាំទ្រផ្លូវចិត្ត និងសម្ភារៈជាច្រើននៅឡើយ ដូច្នេះសមាជិកសហគមន៍ទាំងអស់ចង់ឃើញសាមគ្គីភាព ក្លាយជាជំនួយយ៉ាងជាក់ស្តែង ដែលនឹងធ្វើឱ្យគ្រួសារដែលអ្នកជិតខាងស្រឡាញ់រាប់អានមួយនេះអាចក្រោកឈរវិញបាន៕ **-ពិន សំខុន-**

# បុណ្យកំណើតដ៏មានប្រយោជន៍





**ហ្វីឡាដែលហ្វៀ :** យុវជន ធិន ថាច់ ហៅ ថម ដែលចាបរីកចំរើនដុះដាល ដោយសារសមាគមខ្មែរ តាំងពីយុវវ័យមកជាបុគ្គលិករបស់សមាគម បានការងារធ្វើសមរម្យ បានឮសេចក្តីប្រកាសសមាគមខ្មែរ ថាត្រូវការថវិកា ដើម្បីទ្រទ្រង់សកម្មភាពរបស់ខ្លួន ក៏បានផ្សព្វផ្សាយថា "នាថ្ងៃបុណ្យកំណើតរបស់ខ្ញុំ បើមានមិត្តភ័ក្រ្តបងប្អូនចង់ធ្វើអំណោយដល់ខ្ញុំ ខ្ញុំនឹងយកប្រាក់នេះទៅធ្វើអំណោយជួយសមាគមខ្មែរ"។ ថម គិតថានឹងរៃប្រាក់ឱ្យបាន ៥០០ដុល្លារក្នុងឱកាសមួយនេះ។ គំនិតថ្មីនេះ បានជ្រួតជ្រាប ថម បានទទួលដំណឹងតបពេលយើងចុះព័ត៌មាននេះថា "ពរថ្ងៃខួបកំណើតរបស់ ថម មានអំណោយដល់ទៅ ៣៧៦ដុល្លាររួចហើយ" គំនិតថ្មីធ្វើការបានល្អ ថម !៕






Business For Sale

6 months Opening.
$10,000 including Inventory.
Contact:
Ms. Minh : 267-205-5398
Vivi : 267-205-6876

1136s.11th Street Philadelphia,PA 19147
215-218-3288
Open 7days : 10AM-10PM

តមកទំព័រទី ០១

# ទីក្រុងទ្រីប៉ូលីជិតរលត់...





ការឈប់បាញ់គ្នា ហើយនិយាយចេញមកតែតាមពិតពុំបានបញ្ឈប់សកម្មភាពរបស់កងទ័ពទេ ដែលជាហេតុធ្វើឱ្យសហរដ្ឋអាមេរិក ចេញសេចក្តីសម្រេចចិត្តមួយ លេខ ១៩៧៦ ឱ្យទ័ពណេតូជើងអាកាសចេញទៅទប់ស្កាត់ ។ ទ័ពអាកាសបារាំងមុនគេបានប្រើយន្តហោះចម្បាំងទំនើប ២០គ្រឿងចូលទៅកម្ទេចគោលដៅកាំភ្លើងធំ និងរថក្រោះយោធាលីប៊ី នាល្ងាចថ្ងៃសៅរ៍ភ្លាមនោះ។ បន្ទិចក្រោយមកទ័ពសហរដ្ឋអាមេរិក និងអង់គ្លេសបានបាញ់កាំជ្រួចតូម៉ាហាត សំដៅគោលដៅយោធា ហើយនិងវិមានប្រធានាធិបតីនៃទីក្រុងប៉ូលី ដោយមានយន្តហោះប្រដេញច្រើនគ្រឿងចូលរួមប្រយុទ្ធមិនឱ្យទ័ពអាកាសលីប៊ី ហោះចេញបានឡើយ ។

មកដល់ថ្ងៃទី២២នេះ គេនៅពុំទាន់ឃើញមានសញ្ញាណាមួយថា កាដាហ្វី នឹងបកថយក្រោយសកម្មភាពឧក្រិដ្ឋកម្មរបស់ខ្លួនឡើយ ។ លោក គ្លីនតុន និយាយថា "ទ័ពកាដាហ្វីកំពុង ប្រឈមមុខនឹងការយល់ខុសរបស់ខ្លួន ការបញ្ឈប់បាញ់គ្នា ត្រូវតែបញ្ឈប់ជាបន្ទាន់"! ។

ការវាយលុកតាមផ្លូវគោក ពុំទាន់ទទួលការអនុញ្ញាតិនៅឡើយ តែមតិសាធារណៈបាន និយាយថា "ជីវិតនយោបាយ កាដាហ្វី នៅមិនយូរឡើយ" ។

*-ខ្មែរប៉ុស្តិ៍-*







# ត្រូវការការងារ ? ត្រូវការគុណប្រយោជន៍ល្អ ?

*ឆក់យកឱកាសនឹងកម្មវិធីដែល* **Penn Asian Senior Services** *មាន:*



Penn Asian Senior Services

PASSi

*For a better life at home*

**ធ្វើជាអ្នកជំនួយថែរក្សាសុខភាពនៅផ្ទះ** (Home Health Aide) :

* ការហ្វឹកហ្វឺនតំលៃ 4១000 នឹងផ្តល់ជូនអោយកូនសិស្សដោយឥតគិតថ្លៃ
* ពេលវេលាហ្វឹកហ្វឺនតែ ៨០ ម៉ោងប៉ុណ្ណោះ ហើយអាចផ្លាស់ប្តូរបាន
* ថ្នាក់រៀនចាប់ផ្តើមនៅក្នុងនិទាឃរដូវ (រដូវផ្ការីក) ឆ្នាំ ២០១១ នេះ
* ថ្នាក់រៀននឹងជួបគ្នានៅ Asian Arts Initiative, Chinatown

**ធ្វើជាអ្នកជំនួយការគិលានុបដ្ឋាក** Certified Nursing Assistant (CNA):
**កម្មវិធីជំនួយគិលានុបដ្ឋានៅក្នុងនិទាឃរដូវ (រដូវផ្ការីក) និងរដូវក្តៅឆ្នាំ ២០១១**

* មានជំនួយក្នុងថ្លៃសាលា1
* រួមទាំងឯកសណ្ឋាន ផ្លាកអត្តសញ្ញាណប័ណ្ណ និងសៀវភៅមេរៀន !
* កម្មវិធីមានរយៈពេល ៦ អាទិត្យកន្លះ ( ការហ្វឹកហ្វឺនចំនួន ១២០ ម៉ោង)
* ថ្នាក់រៀនជាភាសាអង់គ្លេស
* ការហ្វឹកហ្វឺនចាប់ផ្តើមនៅក្នុងនិទាឃរដូវ (រដូវផ្ការីក) ,រដូវក្តៅឆ្នាំ ២០១១
* ថ្នាក់រៀនតែក្នុងពេលល្ងាច មានពី( ម៉ោង៥:០០ ដល់ ម៉ោង៩:០០)
* ថ្នាក់គ្លីនិកមានក្នុងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យនៅ Rydal Park (1515 The Fairway, Rydal, PA 19046) ពីម៉ោង ៧:៣០ ព្រឹក ដល់ម៉ោង ១:៣០ រសៀល និងពីម៉ោង ៧:៣០ ល្ងាចដល់ម៉ោង ២:០០ រសៀល

**តម្រូវការតម្រូវការ**

* ត្រូវចេះអាន សរសេរ និងនិយាយភាសាអង់គ្លេសក្នុងកំរិតថ្នាក់ទី ៦ (នឹងមានធ្វើការវាយតំលៃផ្នែកភាសាអង់គ្លេស)
* មានសញ្ញាប័ត្រមធ្យមសិក្សា ឬ សញ្ញាប័ត្រ GED ក៏មានអាទិភាព ប៉ុន្តែមិនទាមទារទេ
* ប្រឡង Mantoux (PPD) ពីរដំណាក់កាល
* ការពិនិត្យរាងកាយ
* ថ្លៃចុះឈ្មោះ 4១00
* ប្រវត្តិរូប
* របាយការណ៍ផ្ទាល់ខ្លួន (របាយការណ៍ ២ កថាខ័ណ្ឌ សរសេរអំពីហេតុអ្វីបានជាអ្នកចង់ធ្វើជាអ្នកជំនួយការគិលានុបដ្ឋា)
* លិខិតស្នាមដែលបញ្ជាក់ថា អ្នកអាចធ្វើការនៅក្នុងសហរដ្ឋអាមេរិកបាន
* អាចឈរបានយូរ អាចលើកវត្ថុទំងន់យ៉ាងតិចណាស់ ៤០ ផោន ហើយដៃទាំងពីរអាចប្រើការបាន

**ចុះឈ្មោះនៅក្នុងថ្ងៃនេះ!** *ថ្នាក់រៀនមានកំណត់*

*ព័ត៌មានបន្ថែមសូមទូរសព្ទមកកាន់ Jenny Sanchez តាមរយៈលេខ 215.572.1234*

**រៀនភាសាអង់គ្លេស :**

* រៀនភាសាអង់គ្លេស ត្រៀមខ្លួនដើម្បីអាជីពក្នុងផ្នែកសុខាភាព
* ថ្នាក់វិជ្ជាជីវៈភាសាអង់គ្លេសជាភាសាទីពីរ Vocational English as a Second Language (VESL)
* ថ្ងៃទី ២៦ ខែមេសា ដល់ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១១

*នៅ **Penn State Abington**

រាល់ថ្ងៃអង្គារ៍ និងថ្ងៃព្រហស្បតិ៍ ពីម៉ោង ៥ ដល់ម៉ោង ៨ល្ងាច
ថ្ងៃសៅរ៍ ពីម៉ោង ៩ព្រឹក ដល់ម៉ោង ៣រសៀល
តំលៃ: $100 ថែមទាំងតំលៃសៀវភៅ ($60)

**ចុះឈ្មោះនៅក្នុងថ្ងៃនេះ!** ថ្នាក់រៀនមានកំណត់

*ព័ត៌មានបន្ថែមសូមទូរស័ព្ទមកកាន់* Jenny Sanchez តាមរយៈលេខ: 215.572.1234

Penn Asian Senior Services 420 Old York Road Jenkintown, PA 19046
ទូរស័ព្ទ: 215-572-1234
ទូរសារ:215-572-1102
គេហទំព័រ: www.passi.u:
អ៊ីមែល info@passi.u

Penn Asian Senior Services
PASSi
*For a better life at home*



# Nationwide®

Nationwide

## Insurance & Financial Service







| Bussiness<br>ធានារ៉ាប់រងជំនួញលោកអ្នក | Home<br>ធានារ៉ាប់រងផ្ទះសម្បែង | Health<br>ធានារ៉ាប់រងសុខភាព | Car<br>ធានារ៉ាប់រងរថយន្ត | Life<br>ធានារ៉ាប់រងជីវិត |
|---|---|---|---|---|

Discount 30% when you purchase
Home & Auto Insurance

ចុះតម្លៃ ៣០% បន្ថែម បើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និង រថយន្តរួមគ្នា

600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257, Fax: (215) 463-2036
**Dong Son, Speak Khmer**



# ភោជនីយដ្ឋាន ឆាយណាស្តារ
## China Star

មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារិន

Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM



យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2

បង្កងឆាខ្ញី និងខ្ទឹមពិសេស $16.95
SPECIAL 2 Lobsters w/ Scallion & Ginger $ 16.95

# PAD THAI

"ផាត់ ថៃ" មានម្ហូប ឡាវ ខ្មែរ និង ថៃ

Lao, Cambodian &Thai Food
1527 Middlesex St. #7 Lowell, MA 01851
Tel: (978) 455-3121
(behind Tae Kwon Do Plaza)



ពិសារក្នុងហាង :
- ភេសជ្ជៈអូដា និងបំពេញបន្ថែមមិនយកថ្លៃ
- មិនយកកំរៃសម្រាប់កុមារអាយុតិចជាង១០ឆ្នាំ

Eat In:
Free soft drink includes refill
Free for Children Under 10 Years Old

ទិញយកចេញក្រៅ :
- ទិញម្ហូប $20 (មុនពាក់) និងបានស្លាបមាន់ឡើន ដោយឥតគិតថ្លៃ

Take-Out:
Purchased with $20 (before tax) get free chicken wings
www.Padthai.foodler.com

Business Hour: Mon. - Sun. 11:00 AM to 9:00 PM
Free Delivery: Mon. - Sun. 11:00 AM to 9:00 PM



# NEW CHINA PEARL
## DIM SUM

288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell 93 South; Exist 37B, from RT-128; Exit 36.

ភោជនីយដ្ឋានញូឆាយណាភើលសូមអញ្ជើញលោកអ្នក និងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។យើងមានសាលធំកំសាន្តសំរាប់ ពិធីការ ឬរាត្រីជួបជុំគ្នាមានបា និងខារ៉ាអូខេទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។

新龍鳳大酒樓

$19.99 Per/person

Sunday Night Buffet Included :
- Lobster/Steak

Restaurant & Bar
ភោជនីយដ្ឋាន និងបា



ភោជនីយដ្ឋាន ញូ ឆាយណា ភើល

Ballrooms for Wedding & Party
មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត

ការ៉ាអូខេ Karaoke
Thursday – Saturday Night
8 p.m. – 11:45 p.m.

មានឌិនស៊ុមរាល់ថ្ងៃ DAILY DIM SUM
Weekdays: 11 a.m.–3 p.m.
Weekends: 10 a.m.-3 p.m.

BUSINESS HOURS: Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight / Sun. 10 a.m. - 10 p.m. Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.

*(Continued from page 01 )*

# A Former Cambodian...

the storeowner received a letter from the court notifying her of James' released. In the letter stated the ordered where James is to stay away from Thach and her family as part of his probation.

"I can't believe he came back here", said Thach who clouted James with a metal rod at the February 28 robbery. James threatened Thach with a knife for the money from the register.

Bo Thach has been a Lynn Resident for nearly 15 years. She is a survivor of the Khmer Rouge regime in the 70s and had lived in various refugee camps with her family as a teen before coming to the United States in 1988.

Thach and her husband of 13 years became the owner of Arnold's Bakery Outlet on Lewis Street in Lynn 8 years ago. While her husband holds a full-time job to secure the family's Health Insurance and mortgage, Thach left to working hard managing the store and business. Thach explained, "I enjoy being a local business owner more and more each year. I get to meet people from all over the world. My customers and I take time to interact." She expressed amusement as she thought of the kind of conversations being held at her store. She recalled, "We even talked politic in this store." Thach is a college graduate with a degree in Bio-Chemistry from Emmanuel College in Boston, Mass.

Thach shared the robberies occurrence will not damage her experience as a business owner, Ironically she said her business had been doing better since the media's highlight on the robbery event last week. She has been receiving cards of support from her customers who praised her for her "heroic act" defending herself and her business against the robber. In one of the card stated, "You are the hero of the community." Thach said one new customer in his late 60s said to her, "It is sad what happened to you, but I am so glad for what you did." as saying.

Thach stated despite the two robbery experiences she felt Lynn is still a good city to live and that there are good people living in Lynn. She said, "I met people from all walks of life and learned so much from them, just in my store alone. They are good neighbors, college students, professors, and even a TV producer as well. These people inspired me to be a proud Lynner."

Speaking like a true survivor of the Khmer Rouge regime and refugee life Thach said with determination, "We don't let this kind of event [robbery] hindered our way of making a living." As for the robber, he was arrested on Thursday, March 3, 2011 and was arraigned in Lynn District Court on a charged of armed robbery and ordered held without bail pending a dangerousness hearing.




បណ្ណជាវប្រចាំកាសែតខ្មែរប៉ុស្តិ៍
ឈ្មោះ និងអាសយដ្ឋានរបស់
ឈ្មោះ : ....................................................................
អាសយដ្ឋាន : ...............................................................
ខ្ញុំចង់បាន :
☐ កាសែតខ្មែរប៉ុស្តិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប
☐ សៀវភៅរឿងឈ្មោះ ............................តម្លៃ $.................
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអដ៌រ មក U.A.M.G តម្លៃ $.................
ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120
**Phone : 267-253-3947**



# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



# ANGKOR AUTO SERVICE,INC.

# ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**

BODY WORKS
Auto glass and windshields
Auto Frame Straightening and Painting



មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមាន សញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបង់របស់ អិនស្វ៊ូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

# ឱសថស្ថាន TRX Pharmacy

5520 Whitaker Ave Unit C, Philadelphia, PA 19124

Tel: 215.288.8701 | Fax: 215.288.8702

Hours : Mon-Fri: 9:30 AM to 6:30 PM Sat-Sun: 10 AM to 4 PM

## ម្ចាស់ហាង : ស៊ីវ អេង

- យើងទទួលយកអ៊ិនស្ទ័រន្សស្ទើរតែទាំងអស់
- កន្លែងចតឡានធំទូលាយ
- អាចយកថ្នាំទៅជូនដល់ផ្ទះ
- សេវាត្រឹមត្រូវច្បាស់លាស់ មានវិជ្ជាជីវៈ ធ្វើការលឿន
- មានគម្រោងបង់ថ្លៃពិសេស សម្រាប់ "ខូប៉េយ" ដែលមានតម្លៃខ្ពស់
- មានរង្វាន់ បើយកវេជ្ជបញ្ជាមកទិញថ្នាំ
- ពិសេស: មានជូនកាំរ៉េ $5 សម្រាប់អ្នកមកទិញថ្មី ដែលមានការផ្ទេរវេជ្ជបញ្ជា

## Diabetes Test Strips ម្ជុលសំរាប់ធ្វើតេស្តទឹកនោមផ្អែម



$32.99/50ct $32.99/50ct $42.99/50ct $85.99/100ct $32.99/50ct $45.99/50ct $38.99/50ct $85.99/100ct



$12.99 $17.99 $12.99

ចុះថ្លៃ 25% →





ចុះថ្លៃ 20% →



6 Bottles = $50.00

**ពិសេស** : ជូនម្សៅអិនស្ទួមួយកំប៉ុងពេលទិញតាមវេជ្ជបញ្ជា៨មុខមានពិសេសសំរាប់ភ្ញៀវដែលគ្មាន អិនស្វិន មានថ្នាំជេណេរីត ច្រើនរយមុខតម្លៃ $7.99 សំរាប់ ៣០ថ្ងៃ ថ្នាំ អនតាយបាយូទិក ដូចជា Amoxicillin, Cephalexin, Pencillin តម្លៃ $4 តាមវេជ្ជបញ្ជាមានលក់របស់ក្មួនក្មេងលេងជាច្រើនទៀត



# ការិយាល័យច្បាប់

## ERIK B.JENSEN P.C

*A Profesional Corporation*



**We Handle All INJURY CASES**

- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

**Criminal Defense – DUI**

Adult & Juvenile

Felonies / Misdemeanors / Drug Offenses

Weapons Charges / Murder / Manslaughter

Robbery / Burglary / Theft / Rape / Child Abuse

Drunk Driving / Traffic Violations

**BANKRUPTCY**

Sheriff Sales / Foreclosures / Repossessions

Credit Repairs / Tax Liens

**FAMILY**

Divorce / Support

Alimony / Child Custody

Protection From Abuse

Visitation / Adoptions

**REAL ESTATE**

Commercial – Residential

Buying / Selling

Settlements / Closings

**BUSINESS**

Contracts / Negotiations

Litigation

Start-ups / Financing

Collections

**TAX PROBLEM**

IRS Disputes / Tax Fraud

Audits / Liens / Levies

Tax & Estate Planning

Wills, Estates & Trusts Social Security

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law

215-546-4700 24 HOUR AVAILABILITY 800-522-6606

1528 Walnut St., Suite 1401 Philadelphia

មានអ្នកបកប្រែភាសាខ្មែរ

Rely On Over 26 Years Of Experience



WWW.ERIKJENSENLAW.COM

we have Khmer staff



Voun Lay, BS

Marketing Coordinator

267-738-7006

# APARTMENT FOR SALE



4 Apt Units on 3rd & Grant Ave.
Northeast Phila, PA

Each/1 Bed, 1 Bath, Living room & Kitchen.Currently occupied. Generate Immediate Income.

**Asking Price $230.000.**

Contact: 267-242-5428

# ខ្មែរប៉ុស្តិ៍ស.រ.អា

"ខ្មែរប៉ុស្តិ៍" ត្រូវការជ្រើសរើសបុគ្គលិកផ្នែកទីផ្សារ នៅតំបន់ឡូវែល និងប្រូវីដិន
មានកំរិតខ្ពស់ បើមានចំណាប់អារម្មណ៍សូមទំនាក់ទំនងមក :
សុបិន : **(267) 253-3947**, សែម : **(781) 244-0522**



# ការិយាល័យមេធាវី ដ័រេង និង បរូស្គី

## LAW OFFICE DOERING & BOROWSKY, LLC

**ទទួលការពារផលប្រយោជន៍លោកអ្នក ករណីទូទៅតាមផ្លូវច្បាប់ដូចជា :**

. ករណីបើរបរពាណិជ្ជកម្ម និងផ្ទេរប្រាក់ក្នុងមុខជំនួញ
. ករណីទិញលក់អចលនវត្ថុ ដូចជាផ្ទះសម្បែង ដីធ្លីជាដើម
. រើសអើងនៅកន្លែងធ្វើការ
. ករណីអន្តោប្រវេសន៍



**ធ្លាប់មានបទពិសោធន៍ខ្ពស់ _ផ្តល់សេវាជីនតាមវិជ្ជាជីវៈហើយតម្លៃក៏សមរម្យទៀតផង _យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**

General practice law office handing matters in :
Corporations and business Transations
Real Estate
Work Place discriminations
Immigration
Experienced, professional service and reasonable rate Interpreter available

Office: (215) 667-8118 1650 Market st. Ste 3600 Philadelphia, PA 19103
Cell: (215) 840-1364; Email: dblawyers@gmail.com

# YOU DON´T HAVE TO LIVE WITH BACK OR NECK PAIN

## លោកអ្នកមិនចាំបាច់រស់នៅជាមួយការឈឺខ្នង ឬកញ្ចឹងកធ្វើអ្វី !



Your Health Comes From your spine

**សុខភាពរបស់លោកអ្នក មកពីឆ្អឹងត្រគៀកខ្នង**

-Constant Backpain -ឈឺខ្នងជាប្រចាំ
-Nagging neck pain -ឈឺកញ្ចឹងកមិនឈប់
-Headaches - ឈឺក្បាល
-Slip & Falls -រអិល និងដួល
-Auto Accidents -គ្រោះថ្នាក់រថយន្ត

Pine Chiropractic & Rehab

**978-452-1188**

# Yoo's Auto Service and Collision

## យូ បំរើសេវារថយន្ត

និងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។




189 W. Duncannon Ave. Phila., PA 19120

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION
Khmer Post

**ពេទ្យម៉ាស៊ីន**

Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission Inspection & Repairs
Muffler & More

**ពេទ្យជួសជុលតួរថយន្ត**

Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

**ទូរស័ព្ទលេខ SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475**

# ការបង្រួបបង្រួមអ្នកប្រជាធិបតេយ្យឆ្ពោះទៅរកភាពជោគជ័យ

**ខ្មែរប៉ុស្តិ៍ : អ៊ិត សុខា**

•••ក្រុមការងារបង្រួបបង្រួមរវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស កាលពីថ្ងៃ ទី26 ខែកុម្ភៈ ឆ្នាំ2011កន្លងទៅ បានចេញសេចក្តីប្រកាសរួមគ្នាមួយស្តីពីក្រុមការងារគណបក្សទាំងពីរដែលបានធ្វើការចរចាដើម្បីបង្រួបបង្រួមឆ្ពោះទៅរកចលនាអ្នកប្រជាធិបតេយ្យដើម្បីការផ្លាស់ប្តូរ ។ នៅក្នុងខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មានរបស់គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានឱ្យដឹងពីលទ្ធផលមួយចំនួនដែលបានកើតចេញពីការចរចារយៈពេល3ដងកន្លងមកកាលពីដើមឆ្នាំ 2011នេះ បន្ទាប់ពីការខកខានចរចារយៈពេល ពីរឆ្នាំ ។

បើយោងតាមខ្លឹមសារប្រកាសព័ត៌មានតាមការចរចាគ្នារយៈពេលបីដងកន្លងមកបានឱ្យដឹងថា ក្រុមការងារនៃគណបក្សទាំងពីរមានការយោគយល់គ្នាកាន់តែច្រើនឡើងលើបំណងរួម ហើយសម្រេចធ្វើការរៀបចំឱ្យមានលក្ខន្តិកៈមួយសម្រាប់ប្រើប្រាស់នៅពេលរួបរួម និងចេញជារូបរាងនាពេលខាងមុខនេះ។

ថ្លែងបញ្ជាក់បន្ថែមពីលើសេចក្តីប្រកាសព័ត៌មាន លោកស្រី មូរ សុខហួរ អ្នកនាំពាក្យនៃក្រុមអ្នកចរចារបស់គណបក្ស សម រង្ស៊ី បានថ្លែងបន្ថែមថា ឆ្លងតាមរយៈការចរចាកន្លងមក គឺបានលទ្ធផលល្អជាជំហ៊ានៗឆ្ពោះទៅរកភាពជោគជ័យនៅពេលខាងមុខ ។

លោកស្រី មូរ សុខហួរ បានថ្លែងបញ្ជាក់យ៉ាងដូច្នេះថា *"ក្នុងកិច្ចប្រជុំនោះ យើងជាគណៈកម្មការក្រុមការងារទាំងពីរដែលមកពីគណបក្ស សម រង្ស៊ី ដឹកនាំដោយលោក ស៊ុន ឆៃ និងមកពីគណបក្សសិទ្ធិមនុស្សដឹកនាំដោយលោក សឹន សូប៊ែរ យើងបានជជែកអំពីគោលបំណងដ៏ចម្បង និងស្មារតីចម្បងនៃការបង្រួបបង្រួមរវាងគណបក្សទាំងពីរ ។ លើស្មារតីនៃការបង្រួបបង្រួមមាន3ចំណុច : ចំណុចទី 1 ការបង្រួបបង្រួមនៃគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស គឺនឹងបង្កើតឱ្យមានចលនាប្រជាធិបតេយ្យដែលមានទ្រង់ទ្រាយទូលំទូលាយ ។ ចំណុចទី2 ការបង្រួបបង្រួម នេះនឹងឈរលើលក្ខខណ្ឌនៃប្រជាធិបតេយ្យដែលទទួលបានពីគណបក្សទាំងពីរ ហើយចំណុចទី3 ចលនាអ្នកប្រជាធិបតេយ្យនេះនឹងមានយូរអង្វែង មិនមែនសម្រាប់មួយគ្រាខ្លីទេ ។ ឈរលើស្មារតី និងចំណុចទាំងបី យើងនឹងបន្តទៅទៀតដើម្បីមើលទៅលើលក្ខខណ្ឌនៃគណបក្សរៀងៗខ្លួនដើម្បីយកមកពិចារណាទៅមើលលើចំណុចរួមមួយគឺវចនាសម្ព័ន្ធទៅមុខ ព្រមទាំងរបៀបសម្រេចនៃវចនាសម្ព័ន្ធទៅមុខនៃចលនាប្រជាធិបតេយ្យនេះ និងធ្វើសេចក្តីសម្រេចនៅលើបញ្ហាចំណុចធំៗដែលត្រូវតែដោះស្រាយ ហើយយើងចាប់លើចំណុចទាំងពីរនេះ យើងត្រូវតែបង្កើតឱ្យមានលក្ខន្តិកៈរួមមួយដែលគណបក្សទាំងពីរអាចទទួលយកបាន គឺចំណុចទាំងបីនេះឯង ។ ស្មារតីយើងជាស្មារតីអ្នកប្រជាធិបតេយ្យ ស្មារតីយើងដែលយកលក្ខខណ្ឌនៃប្រជាធិបតេយ្យមកជជែក និងមកបង្កើតនូវចលនាប្រជាធិបតេយ្យដែលមានទ្រង់ទ្រាយធំ ហើយនិងទី3បំណងរបស់យើង គឺបង្កើតនូវចលនាប្រជាធិបតេយ្យមួយដែលប្រព្រឹត្តិទៅដ៏យូរអង្វែង មិនមែនសម្រាប់រយៈពេលខ្លីនោះទេ ។ ស្មារតីគណបក្សទាំងពីរដែលឈរលើលក្ខណៈប្រជាធិបតេយ្យ បង្កើតឱ្យមានចលនាអ្នកប្រជាធិបតេយ្យដ៏ទូលំទូលាយ ហើយយូរអង្វែង"* ។



លោក កឹម សុខា



លោក សម រង្ស៊ី

សម្រាប់ឯលោក គាត សុគន្ធ អនុប្រធានគណបក្សសិទ្ធិមនុស្ស និងជាក្រុមការងារចរចាបានថ្លែងមិនខុសពីលោកស្រី មូរ សុខហួរ ប៉ុន្មានទេ ដោយលោកថា ក្រុមការងារគណបក្សទាំងពីរបានយល់ព្រមលើលក្ខខណ្ឌទូទៅចំនួនបីចំណុច ។

ក្រុមការងារទាំងពីរបានយកលក្ខន្តិកៈរបស់គណបក្សទាំងពីរយកមកធ្វើជាមូលដ្ឋានគ្រឹះដើម្បីធ្វើការពិចារណា *យើងនឹងសម្រេចយកលក្ខន្តិកៈរបស់គណបក្សទាំងពីរនេះយកមកធ្វើជាមូលដ្ឋានគ្រឹះដើម្បីពិចារណាមើល បូកផ្សំគ្នាទៅដើម្បីឱ្យចេញទៅជាលក្ខន្តិកៈមួយស្របទៅតាមអ្វីដែលយើងបានព្រមព្រៀងគ្នាលើបីចំណុចខាងលើ ។ ខ្ញុំឃើញថាលទ្ធផលជាវិជ្ជមានហើយ ដូចខ្ញុំបានជម្រាបពីមុនថាយើងបានទៅមួយជំហានម្តងៗ ដូច្នេះខ្ញុំមើលឃើញថា ទាំងអស់គ្នាមានគោលបំណងដូចគ្នាហើយ អ៊ីចឹងយើងត្រូវធ្វើយ៉ាងម៉េចដើម្បីឱ្យចេញជារូបរាង ។ ខ្ញុំជឿថាលទ្ធផលនោះនឹងបានជាវិជ្ជមានទៀត"* ។

គម្រោងនៃសម្ព័ន្ធភាពរបស់គណបក្សប្រឆាំងទាំងពីរនេះ បានកើតឡើងនៅដើមឆ្នាំ២០០៩ ពីរឆ្នាំកន្លងមកបានលទ្ធផលជាផ្លែផ្កាបន្តិចបន្តួច តែពុំមែនជាការអស់សង្ឃឹមសោះនោះទេ ៕







Cambodian New Year Celerbration
Proudly hosts by KhmerPost USA
Printing The Cambodian World News
បុណ្យចូលឆ្នាំថោះ ២៥៥៥ជាមួយ ខ្មែរប៉ុស្ដិ៍
នៅសហគមន៍ លីន រីវ រដ្ឋម៉ាសាឈូសេត
ថ្ងៃសៅរ៍ ទី២៣ មេសា ឆ្នាំ២០១១
ម៉ោង៦ល្ងាចដល់១១យប់
•បង្ហាញម៉ូដ សំលៀកបំពាក់ខ្មែរ
•ពិសារម្ហូបខ្មែរ ដោយភោជនីយដ្ឋានខ្មែរ
•ឆ្នោតវត្ថុផ្សងសំណាង ដោយក្រុមពាណិជ្ជករ-សិប្បករ
•រាំកំសាន្តជាមួយ ក្រុមតន្ត្រីវាយោ
•ទិញភេសជ្ជៈនៅបារ៍
Saturday, April 23rd 2011 6PM-11PM
American Legion (Post 6)
157 N. Common St. Lynn, MA
• Cambodian Fashion Show
• Authentic Cambodian food
• Cash Bar
• Social Dance with Veayo Band
• Raffle Prizes
Join Us and Have a Chance Win $3,500 in Gift Certificates To the East Coast Center for Laser & Plastic Surgery
1st Prize: $2,000
2nd Prize: $1,000
3rd Prize: $500
Advanced Tickets: $30/ after April 17: $35 ទិញសំបុត្រមុនថ្ងៃ១៧ មេសា តម្លៃ $៣០ ក្រោយថ្ងៃនេះតម្លៃ$៣៥
Available at: Cheysak Market. 519 Western Ave. Lynn,MA Ph. (981) 477-0115
មានលក់នៅ: Chopstix Restaurant. 855 Western Ave. Lynn,MA Ph. (781) 584-4343
Soben Pin 267-253-3947/ KhmerPostUSA@gmail.com
Sophallina Tim (617) 968-1039/ Sam Khoeun (781) 244-0522